# វគ្គ ការពិតរបស់ប្រពន្ធ

ចន្ទកានបើកភ្នែកព្រឹមៗឡើង ក្រោយពីមានរាត្រីទឹកឃ្មុំមួយចម្លែកឥតមានចម្លើយ។

យប់ផ្សំដំណេកមួយ ដែលសែនសកម្មបានបញ្ចប់ទៅក្នុងសភាពមិនដឹងថា មានរឿងអ្វីកើតឡើងទេបន្ទាប់ពីប្តីរបស់ខ្លួនសារភាពថា គេនោះមានរោគចិត្ត ចង់តែបន្តឈុតឆាកស្នេហាមិនព្រមបញ្ចប់។

ពីនេះទៅខាងវេរ៉ង់ដានៅមុខបន្ទប់គេង ស្រស់ឃើង មើលឃើញខ្នងប្តីកំពុងតែហាត់ប្រាណប្រទាញខ្លួនគេចុះឡើង ដោយមិនដឹងថាតួចកម្សត់តាមសម្លឹងមកពីលើគ្រែដោយស្ងាត់ស្ងៀម។

លុះដល់គេមានអារម្មណ៍ថានាងភ្ញាក់ដឹងខ្លួន ប្រុសក៏បែរមកវិញភ្លាមដោយធ្វើមុខមាំ។

កានខំញញឹមដាក់ប្រុសស្នេហ៍ពេលឃើញគេងាកមកសម្លឹងតែគេនៅតែប្រកាន់មុខ ដូចជាខ្មាំងសត្រូវមិនញញឹម ឬសូម្បីតែស្រទន់បន្តិចក៏មិនបាន គឺគ្មាន។

បើបាននាងញញឹមមកម៉ូស្តាកាន់តែខំធ្វើមុខមាំឡើងលំដាប់។ ប្រុសងាកចេញបន្តហាត់ប្រាណពីរបីក្បាច់ទៀតទុកឲ្យនាងសម្លឹងតាមចិត្ត។

អស់ចិត្តអស់ចង់ ម៉ូស្តាទើបបែរខ្លួនដើរចូលមកវិញ។ ខ្លួនគេពីលើដល់ក្រោមបែកញើសគ្រាប់ៗពាសពេញទាំងរាងកាយណែនមាំ។

ភ្នែកមាណវីកំពុងសម្លឹងរូបរាងប្រុសស្នេហ៍ដែលសែនសង្ហា បិទបាំងតែជាមួយខោកីឡាខ្លីមួយ។

នាងវាចាទៅកាន់រៀមបង៖

«មានរឿងអី? ម៉េចកានគេងដល់ថ្នាក់នេះមិនបានធ្វើអាហារពេលព្រឹកសម្រាប់ប្តី!»

ម៉ូស្តាមិចភ្នែកតាមសម្លឹងអាការៈរបស់ភរិយាសម្ងប់។ ចិត្តប្រុសចង់ដឹងណាស់ថានាងនេះកំពុងលេងល្បិច ឬមួយក៏នាងពិតជាមិនបានខឹងរឿងកាលពីយប់មែន។

ដើរមកដល់ឃើញនាងធ្វើមុខក្រៀម ប្រុសក៏លូកដៃស្តាំទៅស្ទាបថ្ងាសកែវល្អ។

នាងបាត់ក្តៅហើយ ។

គេមិនមាត់តែធូរចិត្តណាស់ដែរ។

ឃើញដៃប្រុសស្អាតប្រមូលសីរ៉ាំងនិងប្រអប់ថ្នាំខ្លះ បោះចោលខ្លះ យកទុកក្នុងកាបូប ចន្ទកាន្តតាមសម្លឹងគេដោយងឿងឆ្ងល់នាងមិនដឹងថាខ្លួនឯងយប់មិញបានសន្លប់នៅមុខបន្ទប់ទឹក ត្រូវបានស្វាមីលើកមកដាក់លើគ្រែទេ ក៏មិនដឹងថាខ្លួនឯងឡើងកម្តៅដែរ។

«អ្នកណានឹង? ឈឺអី! ហេតុអីបានជាមានសីរ៉ាំងចាក់ថ្នាំ?»

នាងសួរម្នាក់ឯងគ្មានពាក្យពន្យល់ព្រោះថាម៉ូស្តារៀបចំកិច្ចរួចក៏ដើរសំដៅបន្ទប់ទឹកធ្វើមិនឮ។

គេដូចជាមិនចង់ឆ្លើយឆ្លងជាមួយនាងសោះ។

កានក្រោកឡើងរៀបចំគ្រែ និងខ្នើយក្រាលភួយលម្អនិងមានអារម្មណ៍ថាខ្លួនឯងទន់ពេកណាស់ស្មើពិលថ្ម។ ស្រីក៏ដួលទ្រមទៅវិញលើទទឹងគ្រែ។ ខ្ញុំកើតអីហេតុអីបានជាខ្សោយម្ល៉េះ? សំឡេងរបស់ប្តីកំណាចស្រែកប្រាប់ពីបន្ទប់ទឹកមកវិញ ៖

«ស្លៀកពាក់ទៅ! រៀបចំទៅពេទ្យ!»

«ទៅមន្ទីរពេទ្យធ្វើអី?»

«ប្រហែលអាចជាគ្រាប់ឈាមក្រហមធ្លាក់!»

«អ្នកណាគេគ្រាប់ឈាមក្រហមធ្លាក់?»

នាងសួរដោយស្រទន់ទៀតព្រោះមិនដឹងរឿង គេវិញឆ្លើយក្រងូវៗ៖

«ចូលមក! សួរនាំច្រើនណាស់ តិចទុកឱ្យចូលមឈូសទាំងទើបរៀបការម៉ែ្វ!»

ស្វាមីថាឱ្យ តូចក៏ឈប់សួរនាំរួចក្រោកឃឹតៗទៅតាមបញ្ជាមនុស្សសម្តីដ៏អាក្រក់ ដែលទើបនាងទើបតែរៀបការជាមួយ។ ស្រស់ស្រីដើរចូលបន្ទប់ទឹកក៏ឃើញគេកំពុងត្រាំខ្លួនជាមួយទឹកក្តៅយ៉ាងសង្ហា ចំណែកខ្លួននាងមើលមកខ្លួនឯងក្នុងកញ្ចក់ទើបដឹងថា ស្លេកស្លាំងដូចមនុស្សខ្វះជាតិដែកធ្ងន់ធ្ងរ។ លើកញ្ចឹងកបន្សល់នូវស្លាកស្នាមក្រហមជាំដោយស្នាមថើបរាលដាលខ្លាំងៗមិនមេត្តាកាលពីយប់ផង។

«ខ្ញុំនេះខ្វះឈាមក្រហម? ហើយម៉េចក៏ប្តីខ្ញុំនិយាយមើលទៅគេហ្នឹងជាពេទ្យ? គ្រែងប៉ាថាគេជាអ្នករកស៊ីធម្មតានោះអី?»

ពេលនាងរៀបការជាមួយម៉ូស្តា គឺមកតែពីប៉ានាងបានពេញចិត្តគេជាខ្លាំង។ មិនត្រឹមដោយសារតែគេបង្ហាញភស្តុតាងមុខជំនួញជាច្រើន ផ្ញើខ្សែកបន្តោងពេជ្រកម្រដល់កូនស្រី និងបង្អួតបណ្ណាការជាលុយសុទ្ធច្រើនហួស។

ឥឡូវនេះទើបតែរៀបការបានមួយយប់ ក៏ជាថ្ងៃទីពីរដែលនាងបានជួបមុខគេ។ ពីមុនមក

កាននៅមិនដែលស្គាល់គ្នាជាមួយគេទេ មិនដឹងថាគេស្រឡាញ់នាងតាំងពីពេលណាមកបានជាហ៊ានឲ្យបណ្ណាការច្រើនលើសលប់ គ្រាន់តែដឹងថាគេជានិស្សិតទើបមកពីបរទេសទទួលមរតកពីឪពុកម្ដាយដែលស្លាប់បាត់អស់ ប៉ុន្តែសីរ៉ាំងកាលពីយប់និងរបៀបគេស្ទាបនាង រឿងនេះប្រាប់នាងឲ្យមើលទៅគេដូចជាពេទ្យម្នាក់ធ្លាប់រៀនពេទ្យ។

«ប្ដីខ្ញុំជាអ្នកណាទៅ?»

កែវតូចនិយាយម្នាក់ឯងតិចៗ ដោយម្ដងៗលួចលបបែរសម្លឹងទៅគេ។ ភ្នែករបស់មូស្តាដែលកំពុងតែសំងំស្ងប់ស្ងាត់ទាមទារយកសេចក្ដីសុខពីអាងទឹកក្ដៅស្រាប់តែគេបានបើកភ្នែកឡើងមកវិញយ៉ាងបង្ខំ។

មិនដឹងយ៉ាងម៉េច កានចេះតែភ័យចំពោះទឹកមុខកាចរបស់គេ។

«យប់មិញនៅកន្លែងនេះ បងប្រាប់អូនថា បងមានរោគ!»

»រោគស្អី?»

«គឺ គឺរោគដែល...ធ្វើឱ្យផ្សំដំណេកមានចំនួនច្រើនដងនៅក្នុងយប់ទីមួយ!»

មូស្តាសើចក្អាកក្អាយ មិនងាកមកមើលប្រពន្ធតូចដែលធ្វើមុខល្ងង់ៗទេ។ ធ្វើមុខល្ងង់ៗនោះនាំតែគេសើចអស់ចិត្តអស់ចង់ ទុកឲ្យនាងឈរនៅឆ្ងល់អស់ចិត្តដែរ។

បន្ទាប់មកម៉ូស្តាចាប់ផ្ដើមក្រឡេកមករកប្រពន្ធនេះសម្លឹងនាងពីជើងដល់ក្បាល។

គេគិតម្ដេចមិនដឹងក៏ចេញបញ្ជា៖

«លុបលាងតែមុខមាត់ដុសធ្មេញស្លៀកពាក់ទៅ មិនចាំបាច់ងូតទឹកទេ អាការៈអាចខ្សោយខ្វះឈាម!»

នាងធ្វើមុខស្មើ អន់ចិត្តនឹងសុខភាពខ្លួនឯង។

ស្រីសម្លឹងខ្លួនឯងក្នុងកញ្ចក់រអ៊ូតិចៗម្នាក់ឯងថា៖

«ខ្ញុំស្មានថាជាហើយ! នេះមករើឡើងវិញទៀតទាល់តែបាន!»

ប្រុសធ្វើជាមិនចាប់អារម្មណ៍ ប៉ុន្តែចិត្តគេដូចជាស្រួលឬសប្បាយម្យ៉ាងដែលឮនាងនិយាយថាធ្លាប់មានជំងឺ។

បើសិនជានាងពិតជាខ្វះគ្រាប់ឈាមដូចការស្មានរបស់គេ គម្រោងការទាមទារបំណុលតាមរយៈការធ្វើបាបរូបកាយនាងប្រហែលជាអាចត្រូវកែប្រែខ្លះ។

គេមិនចង់ក្លាយជាឃាតកៈទេហើយក៏មិនចង់ឲ្យអ្នកណាស្លាប់ដែរ គឺចង់ឲ្យរស់នៅតាមរបៀបដ៏ឈឺចាប់មួយ។ ភ្លាមនោះគេបែរទៅវិញ ព្រោះឃើញកានកំពុងតែបើកទឹកក្តៅ រួចពូតកូនកន្សែងតូចមកជូតខ្លួនឯងថ្នមៗ។

ពេលខ្លះកានធ្វើទឹកមុខឈឺចាប់ ពីព្រោះយប់មិញនៅក្នុងរាត្រីដំបូង គេមិនបានស្រាក់ដៃចំពោះនាងឡើយ។ តូចចន្ទកានឈរសម្លឹងខ្លួនឯងក្នុងកញ្ចក់ ជូតរាងកាយអស់ចិត្ត នាងប្រហែលជាចង់ជូតសម្អាតគ្រប់កន្លុកកន្លៀតទើបដៀងភ្នែកដោយញញើតញញើមសម្លឹងទៅស្វាមីដែលមុខស្មើ។

ប្រហែលខ្លាចគេមើលឃើញបានជាតូចលើកដៃទៅទាញវាំងននបិទបាំងជុំកន្លែងដែលខ្លួនកំពុងឈរ។

ឮសូរវនួតវាំងនន ប្រុសស្អាតបើកភ្នែកមកវិញបែរទៅសម្លឹងភរិយា។

ពេលនេះគេឃើញតែកជើងតូចរបស់នាងដែលទម្លាក់កន្សែងពោះគោធំចោលមកលើឥដ្ឋ។ ដៃតូចលូកមករើសលើកកន្សែងយកឡើងទៅទុក ប្រុសដឹងថា នាងសម្រាតមួយរយភាគរយដើម្បីជូតខ្លួនតាមបង្គាប់ប្តី ដែលមិនអនុញ្ញាតឲ្យងូតទឹក។

«ហើយបងម៉ូស្ហាធ្លាប់ធ្វើពេទ្យឬយ៉ាងម៉េច? ម៉េចក៏បងចេះចាក់ថ្នាំ ហើយដឹងថាត្រូវធ្វើម៉េចខ្លះ!»

គ្មានចម្លើយ។ ស្ងាត់ច្រៀប កានគិតថាគេបិទភ្នែកសំងំយកសុខក្នុងពពុះទឹកក្តៅមិនចង់ឆ្លើយឆ្លងជាមួយនាងតាមទម្លាប់របស់គេ។

ចន្ទកានមិនដែលស្គាល់មនុស្សម្នាក់នេះ តែគេឲ្យកិត្តិយសមកដណ្តឹងដល់ប៉ា ធ្លាប់ចេញដើរលេងបានម្តងគេមិននិយាយមិនស្តី មិនដែលប៉ះពាល់នាងមុនថ្ងៃរៀបការថែមទាំងផ្តល់នូវ

បណ្ណាការជាទីគាប់ចិត្តឪពុករបស់នាងខុសពីអ្នកមុនៗដែលចូលមកស្ដីដណ្ដឹងកាលណាមិនដែលត្រូវចិត្តរបស់ឪពុករបស់នាងឡើយ។

យប់មិញនាងលង់ស្រឡាញ់គេយ៉ាងខ្លាំង ដោយសាររូបរាងនិងឫកពាមិនមាត់មិនករបស់គេ ទោះបីយ៉ាងណាចន្ទកានយល់ថាគេនេះកើតមកមិនងាយនិយាយមិនងាយស្ដី ពាក្យគំរោះទ្រគោះទ្រគាំង តែកាននៅតែរក្សាចិត្តស្រឡាញ់គេទាំងឈឺជាប់កាយស្រែកយំហើយនៅតែគិតថានេះជាធម្មជាតិរវាងប្ដីនិងប្រពន្ធ។

កានក៏កាន់តែស្រឡាញ់រូបគេទ្វេឡើង នៅពេលដឹងថាគេបានចាក់ថ្នាំឲ្យនាង និងពេលគេមកពីហាត់ប្រាណ ស្ទាបថ្ពាសធ្វើឲ្យនាងកក់ក្ដៅចម្លែក។ មនុស្សមិនចេះនិយាយផ្អែម មិនចេះថ្នាក់ថ្នម ធ្វើឲ្យការខ្វះអារម្មណ៍កក់ក្ដៅនៅមាន នៅឆ្ងល់នៅខ្លាច  ប្រហែលជាអ៊ុំចឹងបានជា គេប៉ះថ្ពាសតែបន្តិចកានមានអារម្មណ៍អស្ចារ្យច្រើនដល់ហើយ។

«បងបារម្ភប្រពន្ធណាស់មែនទេ?»

នាងនិយាយសួរពីក្នុងនោះមកតាមសន្ទានស្លូតត្រង់របស់ខ្លួន។ នៅតែស្ងាត់ច្រៀបគ្មានចម្លើយ ស្រស់នៅសំកាំងឆ្ងល់ថា គេបាត់ទៅណារួចទើបបន្តជូតខ្លួននិងលាងមុខ។

សូរខ្វាក!

វាំងននត្រូវបើកចេញដោយបង្ខំ។

កានយើងសន្ទឹមៗសម្លឹងទៅក្នុងកញ្ចក់ដោយភ័យៗ ព្រោះនៅពីក្រោយគឺពិតជាស្វាមីដែលធ្វើមុខដូចបិសាចក្រហមង៉ូវ។

គេក៏មិនមានខោអាវគ្រប់តែកន្សែងមួយប្រឡាក់សាប៊ូពាសពេញ។

ព្រោះកានក៏មិនមានអ្វីបន្តិចមកបិទបាំងខ្លួន ទោះប្រុសកាយវិការដូចជាជឿជាក់ខឹនាងវិញក៏នាងចាញ់ប្រាបគេកប់។ កែវទាញកន្សែងមកភ្លាមឱបបិទបាំងបរិវេណខាងមុខដែលពេលល្មបែរទៅរកគេ ឃើញភ្នែកគេនៅតែសម្លឹងទៅត្រគាកនិងដងខ្លួនចង្កេះរាងរាវរបស់កានឆ្លុះក្នុងផ្ទាំងកញ្ចក់។

ទឹកមុខកូនក្រមុំស្រ្តីងឿងឆ្ងល់លាយភ័យព្រួយនិងអង្វរករ បែរជាខាងប្រុសទឹកមុខពោរពេញទៅដោយតម្រេកកាមគុណ។

នាងយល់ថាគេមានតណ្ហាទៀតហើយ ខំតែនិយាយខ្សឹបៗម៉្លឹងចំភ្នែកថ្លែងថា៖

«ទៅពេទ្យមែនអត់? ក្រែងថាឱ្យកានរៀបចំទៅពេទ្យមែនអត់?»

ប្រុសល្អញញឹមញញាក់ៗស្មាព្រោះកាននេះកំពុងខំញញឹមស្ទាក់ស្ទើរ លួងលោមចិត្តខ្លួន ម៉ូស្តាបានចិត្តដូចជាក្បត្រាសោយរាជ្យរបៀបដូចជាសត្វចចកដែលកំពុងឃើញចំណីនៅចំពោះមុខហើយចង់ត្របាក់។ សភាពគេនេះ នាងជួបតែមួយយប់ទទួលបានបទពិសោធច្រើនហើយ កាលណាគេមានដង្ហើមហត់ៗ មុខក្រហមៗ ហើយគ្មានអ្នកណាមកទប់គេឱ្យបកក្រោយសង្វៀនស្នេហារោលរាលបានទេ។ ប្រាកដជាមានឈុតឆាកកើតឡើងនៅកន្លែងនេះតែម្តងមនុស្សចិត្តឆេវដូចគេ។ យប់មិញ៤លើកហើយគេមិនបានជោគជ័យសោះ។ យ៉ាងនេះក៏ដោយកាននៅខំនិយាយខ្សាវៗបន្ថែម៖

«មិនទាន់ញ៉ាំអាហារពេលព្រឹកផង ចាំអូនឆាប់ទៅរៀបចាំនៅក្រោមញ៉ាំជាមួយគ្នា!»

អស់ពីញញឹមឌឺនាង ម៉ូស្តាធ្វើមុខស្មើក្នុងសំឡេងផុតៗដូចហត់នឹងចិត្តដែលញាប់ញ័រគេឆ្លើយខ្លីៗថា៖

«រៀបស្អី! អាហារពេលព្រឹកនៅហ្នឹងហើយ!»

នាងធ្វើមុខក្រហមងាំងអៀននឹងភ្នែកស្រទន់របស់គេកំពុងបុកទម្លុះបេះដូងនាងដល់ទីជម្រៅ។ គេថារឿងមានអីៗជាមួយគ្នា ចាត់ទុកថាជាអាហារពេលព្រឹកមែនទេ? ហួសចិត្តនឹងប្តីម្នាក់នេះ ប៉ុន្តែព្យាយាមនិយាយតាមការពិតជាក់ស្តែងទៀតថា៖

«អូនអស់កម្លាំងណាស់ បងថាខ្ញុំអាចខ្វះឈាមក្រហមហើយកានកំពុងឈឺណាស់ ឈឺគ្រប់កន្លែង!»

សភាពរបស់នាង សម្តីរបស់នាង ម៉ូស្តាថាស្រីស្អាតចង់បដិសេធការទាមទាររបស់គេ។ គេធ្វើមុខមាំ យកដៃទាំងសងខាងបោះកាន់ត្រគាកនាងជេញលេញទាមទារកម្មសិទ្ធិជាប្តី។ ប្រពន្ធមិនហ៊ានច្រានម្នាក់នេះចេញទេ។ នាងមិនទាន់បានរុំកន្សែងត្រឹមត្រូវផង ប្រាណកែវល្អកាន់តែអៀបផូរផង់គាប់ភ្នែកដូចតួកុនជប៉ុន នៅចំពោះមុខទុកត្រឹមជាឈ្លើយស្នេហ៍នៃប្រុសមានឫក។

ព្រោះគេខ្ពស់ជាងនាងខ្លាំង បានជាកន្លែងដ៏មានឫទ្ធិបំផុតរបស់ម៉ូស្តា កំពុងរុញមកបុកប៉ះនឹងកន្សែងនៅពីក្រោមទ្រូងរបស់នាងទាមទារ...។

សំឡេងរបស់គេក៏និយាយមកវិញថា៖

«បើថាកន្លែងហ្នឹងឈឺ ប្រើកន្លែងផ្សេង!»

ស្រីឡិងឡង់មិនយល់ពាក្យប្ដីនិយាយទេ។ សូម្បីតែរឿងអាសអាភាសក៏មិនដែលមើលដែរក្នុងជីវិតនេះ កុំថាបើរឿងទាំងអស់នោះ សូម្បីតែប្ដីជាអ្នកដែលមានប្រវត្តិបែបណាក៏នាងមិនដែលស៊ើប សូម្បីតែដឹងថាគេធ្វើបែប ធ្ងន់ដៃមកលើនាងក៏នាងនៅតែគិតថាជីវិតប្ដីប្រពន្ធគ្រប់គ្នានឹងធ្វើបែបហ្នឹង បានជានាងនៅស្ងៀម នាងស្រែកយំកាលពីយប់ព្រោះអត់ធ្មត់ការឈឺចាប់មិនបានតែនាងមិនបានខឹង។

កែវល្អតាមសម្លឹងភ្នែកគេ ចង់ដឹងច្បាស់ថាចិត្តប្រុសមានស្នេហ៍ស្មើនឹងកំសួលតណ្ហាដែរឬយ៉ាងណា ឯម្រាមដៃគេរេពីលើត្រគាកឡើងសសៀរមកដល់ចង្កេះ ហើយឈប់នៅទីនោះ ទុកឱ្យដៃម្ខាងទៀត ឡើងបន្តមកដល់លើ និងទាញកន្ទ្រាក់ដណ្ដើមកន្សែងប្រុងថាបោះចោលចេញ ។

មិនចង់អាក្រាតបែបនេះ ខាងស្រស់ស្រីគ្មានទេអារម្មណ៍ស្រើបស្រាល មានតែការខ្វល់ថាការបដិសេធរបស់នាងពេលនេះនឹងធ្វើឱ្យគេខឹងសម្បារអាម៉ាស់មុខ តែនាងពិតជាមិនអាចទទួលគេបានទៀតនោះទេ។ តួចស្រវាឱបកាយធំមាំ។

នាងឱបគេស្អិតដូចតុកកែមិនឱ្យគេទាញកន្សែងយកថែមទាំងអង្វរ៖

«ជូនប្រពន្ធទៅពេទ្យសិនទៅណា ហើយជូនប្រពន្ធទៅញ៉ាំអីឆ្ងាញ់ៗ ហើយជូនប្រពន្ធទៅដើរលេងម៉ល  ថតរូបស្អាតៗឱ្យកាន ព្រោះនេះជាថ្ងៃទីមួយដែលយើងរៀបការជាមួយគ្នាណ៎ា!»

ប្រុសស្អាតនេះធ្វើមុខមឹងមាំង ម្ដងក្រញូវម្ដងភាំង មិនដឹងធ្វើបាបមនុស្សស្លូតត្រង់នេះតទៅទៀតដោយវិធីណា។ ប្រុសសម្លឹងតួចដែលកំពុងផ្ទប់ច្រមុះនឹងទ្រូងខ្លួន។

មុននេះរាងកាយសិចស៊ី អៀនប្រៀនទាញរាំងននបាំងនាំឱ្យចិត្តប្ដីមួម៉ៅ ក្រោកមកចង់ធ្វើបាបនាងខ្លះៗទៀត លុះមកឮសម្ដីកាលណា ចិត្តគេម្ដងមួម៉ៅចង់តែច្រានកែវចេញឲ្យបាត់ព្រោះមិនចង់ឲ្យវាចានេះទាក់ចិត្តគេបាន ឯគំនិតមួយទៀតនៅបន្តចង់ដឹងអំពីស្រីម្នាក់នេះខ្លាំងឡើងជាលំដាប់ ថានាងជាព្រះឬក៏ជាមនុស្សគ្មានសមាសភាពខឹងគ្នានៅក្នុងខ្លួនសូម្បីមួយសរសៃឈាម។

កាននិយាយបន្តទៀតពេលប្ដីនៅផ្ទាំង៖

«ហើយបន្ទាប់មកប្ដីជូនចន្ទកាន ទៅទិញស្ករសូកូឡាឈ្មុយៗដើម្បីញ៉ាំឱ្យអស់ចិត្ត!»

មូស្ដាជាមួយភ្នែកងឿងឆ្ងល់មាត់គេសួរខ្សាវៗព្រោះអាណិតកាន គឺសួរនេះមិនបានព្រាងទុក៖

«ឆ្កួតជា? អាយុប៉ុន្មានមែនអត់? មិនដែលបានញ៉ាំស្ករទេ? បបួលប្ដីដើរទិញស្ករគ្រាប់សូកូឡា? មាយាញិកញ័ក់ធ្វើមើលតែខ្លួនឯងនិងទេពអប្សរកំពុងធ្លាក់មកពីលើមេឃ កំពុងរស់មានក្ដីសុខផុតផែនដី?»

កាននៅតែមិនងើបមុខពីរាងកាយណែនក្ដៅគគុកដោយភ្លើងស្នេហ៍។ ស្រីស្រពោនចិត្តនឹកអាណិតខ្លួនឯង ដែលមិនមានអ្នកណាគ្រាន់រំលែកប្រាប់ការពិតនៃឆាកជីវិតយុវវ័យដ៏ឯកោរងាពេលនេះក៏ប្រើដៃទាំងពីរឱបខ្នងគេជាប់ណែន។ កែវតូចសារសព្ទនឹងប្រុសកំពូលដួងចិត្តថា៖

«តាំងពីតូចកានគ្មានម៉ែនោះទេ ប៉ាថែមមិនដែលនៅផ្ទះ គាត់មានសង្សារជាច្រើន គាត់ថាគាត់ស្រឡាញ់កូនណាស់ មិនយកសង្សារណាម្នាក់មកធ្វើម្ដាយចុងឱ្យខ្ញុំទេខ្លាចគេធ្វើបាបខ្ញុំនិងបងខ្ញុំ តែប៉ាក៏មិនដែលនាំខ្ញុំដើរលេងដែរ គាត់មិនដែលឱ្យកានបានមើលកុន ផ្ទះគ្មានអ៊ីនធឺណែត ប៉ាថា កូនស្រីមានអ៊ីនធឺណែតនាំទៅមើលរឿងផ្ដេសផ្ដាស ធ្វើឲ្យមានចរិយាមិនល្អប៉ាចង់ឲ្យខ្ញុំបរិសុទ្ធដូចជាគជ់ មិនឲ្យមានសង្សារ អ្នកណាដណ្ដឹងក៏គាត់មិនងាយយល់ព្រម កានរៀបការសប្បាយចិត្តយ៉ាងនេះព្រោះគិតថាពេលនៅជាមួយប្ដី ប្ដីនឹងឲ្យសេរីភាពខុសពីប៉ា ឱ្យញ៉ាំនំសូកូឡាឈ្ងុយឆ្ងាញ់ ឱ្យដើរលេង ឱ្យបានថតរូប ឱ្យស្លៀកពាក់ស្អាតស្រស់ៗ...»

ខាងប្រុសដែលទាញដៃស្រីប្រុងថា ទម្លាក់ចេញលែងឱ្យឱប មិនចង់ឱ្យនាងមកក្និកក្នក់ឱ្យខ្លួនឯងទន់ចិត្តកាយអាណិតអាចធ្លាក់លង់ស្រលាញ់ តែមិនដាច់ចិត្ត ព្រោះនៅគាំងពេលឮពាក្យនាង។

«តើពិតជាមានគ្រួសារណាធ្វើបាបកូនស្រីខ្លួនឯងរបៀបនេះ?»

គេនិយាយប្រាប់ខ្លួនឯងក្នុងចិត្តថា តើកញ្ញាស់នោះមិនត្រឹមធ្វើបាបអ្នកដទៃថែមទាំងបង្ខាំងកូនស្រីខ្លួនមិនឲ្យស្គាល់ពិភពខាងក្រៅពិតមែនទេ?

គេសួរមួយៗ៖

«ចុះក្រែងបានទៅរៀនណាស់ ដល់ចប់អនុបណ្ឌិតមានអត់?»

«ចាំ ប៉ុន្តែអង្គរក្ស តាមរហូតមិនអាចទៅណា មិនអាចមានមិត្តភក្តិ!»

«ចុះបើមានវាយ៉ាងម៉េច មកពីគ្មានអ្នកស្រុកមករាប់មែនទេ ចួនកាលមកពីគ្រួសារយើងសម្ដែងទ្រព្យសម្បត្តិមើលងាយអ្នកដទៃឬក៏ប្រព្រឹត្តអ្វីមិនល្អ?»

គេថាចប់ក៏រលាស់ខ្លួននាងចេញ។ កានទាញកន្សែងមករុំខ្លួនឯងព្រោះខាងប្រុសមិនព្រមជួយបិទបាំង។ គេគេចពីគំនិតអាណិតកានចេញទៅក្រៅវិញ ទាំងមានស្រីតាមពីក្រោយដើម្បីពន្យល់ប្ដី៖

«កានធ្លាប់មានមិត្តភក្តិ ធ្លាប់មានគេរាប់អាន តែពេលត្រលប់មកផ្ទះវិញម្ដងណាត្រូវរំពាត់ពាសពេញខ្លួន ត្រូវហាមលែងឲ្យទៅរៀន ដូច្នេះដើម្បីបានទៅរៀនក្រោយៗកាននៅម្នាក់ឯង ត្រូវមិននិយាយរកនរណាទាំងអស់!»

គេបែរមកសម្លឹងតូច។ គេគិតថា មូលហេតុនោះហើយនាងក៏ក្លាយមកជាមនុស្សតក់មក់ទុយមួយរហូតដល់ធំឡើងបែបនេះ?

នាងនិយាយបន្តទៀត៖

«កានខំប្រឹងរស់នៅបែបនេះ រំពឹងថ្ងៃណាមួយមានប្ដីម្នាក់ដែលអនុញ្ញាតឲ្យកានធ្វើអ្វីដែលមិនធ្លាប់បានធ្វើ!»

ប្រុសយកដៃចង្អុលទ្រូងនាងហើយហាមដោយមុខស្មើ៖

«កុំសង្ឃឹម កុំមាយា!»

ប្រុសកាចចេញលក្ខណៈមកដូចចង់គេចៗមិនចង់ស្ដាប់តទៅទៀតទេពីព្រោះរឿងទាំងអស់ហ្នឹង ដូច្នេះកំពុងតែធ្វើបាបចិត្តគេយ៉ាងចម្លែក....